ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍វឌ្ឍនភាពប្រចាំខែមករា ឆ្នាំ ២០១៥

រៀបចំដោយអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ

# ១. សេចក្តីផ្តើម

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ (NAA) ឬ អ.ជ.ប.ជ.អ ជាស្ថាប័នជាតិតែមួយ ដែលមានតួនាទី និង ការទទួលខុសត្រូវខ្ពស់ក្នុងការដឹកនាំ គ្រប់គ្រង និងសម្របសម្រួល ការទប់ស្កាត់ការរាលដាលមេរោគអេដស៍ និង ជំងឺអេដស៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការឆ្លើយតប ទូលំទូលាយ និងពហុវិស័យ ដោយមានអគ្គលេខាធិការដ្ឋានជាសេនាធិការ។ ដើម្បីឆ្លើយតបទៅនឹងការទទួលខុសត្រូវនេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ ត្រូវរៀបចំរបាយការណ៍ជាប្រចាំរៀងរាល់ខែដើម្បីបង្ហាញ និងរៀបរាប់ពីវឌ្ឍនភាព និងសមិទ្ធផល ដែលទទួល បានពីការអនុវត្តសកម្មភាព រួមទាំងកិច្ចការនានា របស់ថ្នាក់ដឹកនាំ អគ្គលេខាធិការដ្ឋាន និងនាយកដ្ឋានចំណុះទាំងអស់ដើម្បីឆ្លុះបញ្ចាំងពីអាណត្តិ និងបេសកកម្មរបស់ខ្លួន ស្របទៅតាមគោលដៅអភិវឌ្ឍន៍សហស្សវត្ស របស់រាជរដ្ឋាភិបាលកម្ពុជា និងការអនុវត្តគោលការណ៍បី-មួយ រួមទាំងការគោរពទៅតាមការ ប្តេជ្ញាចិត្តអនុវត្តនូវសេចក្តី ថ្លែងការណ៍ជាសកលរបស់អង្គការសហប្រជាជាតិលើកទី៦៥ កាលពីខែមិថុនា ឆ្នាំ២០១១ ក្នុងការសម្រេចឲ្យ បាននូវគោលដៅជាយុទ្ធសាស្ត្របី-សូន្យឆ្នាំ២០២០ (មិនមានការឆ្លងមេរោគអេដស៍ថ្មី មិនមានការស្លាប់ដោយ សារជំងឺអេដស៍ និងមិនមានការរើសអើង និងមាក់ងាយដល់អ្នកផ្ទុកមេរោគអេដស៍)។

ជាងនេះទៅទៀត អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ មានតួនាទីមួយទៀត នៅក្នុងការរៀបចំចងក្រងរបាយការណ៍ពហុវិស័យឆ្លើយតបការរាលដាលមេរោគអេដស៍ និង ជំងឺអេដស៍ ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ដែលមាននាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ ជាសេនាធិការសម្របសម្រួលក្នុងការរៀបរៀង និងចងក្រង របាយការណ៍នេះ។

សម្រាប់របាយការណ៍ប្រចាំខែ មករា ឆ្នាំ២០១៥នេះ នាយកដ្ឋាន ផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវនៃ អ.ជ.ប.ជ.អ. បានរៀបចំរបាយការណ៍ប្រចាំខែមករា ដែលរួមបញ្ចូលនូវវឌ្ឍនភាពដែលសម្រេចបានពីការអនុវត្ត ផែនការសកម្មភាពរបស់ថ្នាក់ដឹកនាំ អ.ជ.ប.ជ.អ និងនាយកដ្ឋានប្រតិបត្តិទាំង៤ របស់អគ្គលេខាធិការដ្ឋាន ដូចខាងក្រោម:

- វឌ្ឍនភាព និងសមិទ្ធផលដែលសម្រេចបានដោយថ្នាក់ដឹកនាំ អ.ជ.ប.ជ.អ
- វឌ្ឍនភាព និងសមិទ្ធផលដែលសម្រេចបានដោយអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ
- វឌ្ឍនភាព និងសមិទ្ធផលដែលសម្រេចបានដោយ នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ
- វឌ្ឍនភាព និងសមិទ្ធផលដែលសម្រេចបានដោយនាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន
- វឌ្ឍនភាព និងសមិទ្ធផលដែលសម្រេចបានដោយនាយកដ្ឋានបង្ការ ថែទាំ និងគាំទ្រ
- វឌ្ឍនភាព និងសមិទ្ធផលដែលសម្រេចបានដោយនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ទិសដៅការងារសំរាប់ខែបន្ទាប់របស់នាយកដ្ឋាននីមួយៗ

# ២. លទ្ធផល និងសមិទ្ធិផល

## ២.១-លទ្ធផលដែលសម្រេចបានដោយថ្នាក់ដឹកនាំ អ.ជ.ប.ជ.អ

ក្នុងនាមជាថ្នាក់ដឹកនាំ អ.ជ.ប.ជ.អ នៅក្នុងខែមករានេះ ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ រួមជាមួយនឹងថ្នាក់ដឹកនាំ អ.ជ.ប.ជ.អ ទាំងអស់បានដឹកនាំធ្វើសកម្មភាព ស្របតាមតួនាទី និងភារកិច្ច និងសម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

- នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០១៥ ឯ.ឧ. ទេសរដ្ឋមន្ត្រី អៀង មូលី បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំលើកទី៧០ នៃគណៈកម្មាធិការសម្របសម្រួលប្រចាំប្រទេសរបស់មូលនិធិសកល ។កិច្ចប្រជុំមានគោលបំណងសំខាន់បង្ហាញពី ១). សេចក្តីព្រាងឯកសារទស្សនៈទាន ស្តីពីការពង្រឹងប្រព័ន្ធសុខាភិបាល ២). បច្ចុប្បន្ន ភាពកម្មវិធីជំងឺគ្រុនចាញ់ និង ៣). គោលការណ៍ណែនាំរបស់មូលនិធិសកលស្តីពីប្រាក់លើកទឹកចិត្ត តាមគំរូហិរញ្ញប្បទានថ្មី ។ ជាលទ្ធផលនៃអង្គប្រជុំរួមមាន៖
    - បានប្រកាសគណៈកម្មាធិការក្នុងការបោះឆ្នោត គាំទ្រកំណត់បង្ហាញទស្សនៈសម្រាប់ការពង្រឹងប្រព័ន្ធសុខាភិបាល និង គាំទ្រអ្នកទទួលជំនួយផ្ទាល់សម្រាប់ការពង្រឹងប្រព័ន្ធ សុខាភិបាល។
    - បានស្តាប់នូវការផ្តល់សក្ខីកម្មដោយសង្ខេបពី ការចូលរួមស្វែងយល់ក្នុងកិច្ចសន្ទនាថ្នាក់ជាតិស្តីពីប្រជាជនដែលរងផលប៉ះពាល់ ។
    - បានធ្វើការពិនិត្យមើលលើបច្ចុប្បន្នភាពអំពីកម្មវិធីជំងឺគ្រុនចាញ់ដូចជា ៖ ១). លទ្ធផលនៃការជ្រើសរើសអ្នកទទួលជំនួយបន្តពីថវិកាជំនួយតាមគំរូហិរញ្ញប្បទានថ្មី ២). ឯកសារទស្សនៈទានទាក់ទងនឹងជំងឺគ្រុនចាញ់ ការឆ្លើយតបមកវិញពីគណៈកម្មការវាយតម្លៃបច្ចេកទេស ៣). ការរៀបចំឡើងវិញគម្រោងផ្តួចផ្តើមArtemisinin ប្រចាំតំបន់សម្រាប់ជំងឺគ្រុនចាញ់ ។
    - បានធ្វើការពិភាក្សាលើ គោលការណ៍ណែនាំរបស់មូលនិធិសកលស្តីពីប្រាក់ លើកទឹកចិត្តតាមគំរូហិរញ្ញប្បទានថ្មីដោយពិនិត្យមើល៖១). លក្ខខណ្ឌពីមុននៅក្នុងថវិកាជំនួយជំងឺរបេង និង ២). អំពីស្ថានភាពនៃថវិកាលើកទឹកចិត្តដែលបានរៀបចំផែនការនៅក្នុង រាល់ថវិកាជំនួយតាមគំរូហិរញ្ញប្បទានថ្មី ។
    - បានពិភាក្សាទៅលើកិច្ចការផ្សេងៗ ដូចជា៖ ១). សេចក្តីព្រាងកាលវិភាគប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលប្រចាំប្រទេសឆ្នាំ២០១៥ និង ២). ផែនការទស្សនកិច្ចរបស់មូលនិធិសកល នាពេលខាងមុខ ។
- នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០១៥ ឯ.ឧ. ទេសរដ្ឋមន្ត្រី អៀង មូលី បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំលើកទី៦៩នៃគណៈកម្មាធិការសម្របសម្រួលប្រចាំប្រទេសរបស់មូលនិធិសកល ។កិច្ចប្រជុំមានគោលបំណងសំខាន់បង្ហាញពី ១). សេចក្តីព្រាងកំណត់បង្ហាញទស្សនៈអំពីជំងឺអេដស៍ ២). បច្ចុប្បន្នភាពពីកំណត់បង្ហាញទស្សនៈផ្សេងៗ និង ៣).ពិនិត្យមើលសមាជិកភាពគណៈកម្មាធិការសម្របសម្រួលប្រចាំប្រទេស ។ ជាលទ្ធផលនៃអង្គប្រជុំរួមមាន៖
    - បានធ្វើការបោះឆ្នោតគាំទ្រកំណត់បង្ហាញទស្សនៈ និងបោះឆ្នោតគាំទ្រអ្នកទទួលជំនួយផ្ទាល់សម្រាប់ជំងឺអេដស៍ ។

- ○ បានស្តាប់នូវការផ្តល់សក្ខីភាពដោយសង្ខេប ពីការចូលរួមក្នុងកិច្ចសន្ទនាថ្នាក់ជាតិពីក្រុមប្រជាជនដែលរងផលប៉ះពាល់ និង បទបង្ហាញអំពីកំណត់ បង្ហាញទស្សនៈតំបន់ដែលរៀបចំដោយ ក្រុមបណ្តាញប្រជាជនដែលរងផលប៉ះពាល់ក្នុងតំបន់។
- ○ បានធ្វើការពិនិត្យមើលលើបច្ចុប្បន្នភាពពីកំណត់ បង្ហាញទស្សនៈផ្សេងៗដូចជា ៖ ១). បច្ចុប្បន្នភាពនៃថវិកាជំនួយជំងឺរបេង(ការចុះហត្ថលេខាលើថវិកាជំនួយ)២).បច្ចុប្បន្នភាពថវិកាជំនួយជំងឺគ្រុនចាញ់ (ការរៀបចំថវិកា/ការជ្រើសរើសអ្នកទទួលជំនួយបន្ត) និង ៣). បច្ចុប្បន្នភាពនៃ ការរៀបចំកំណត់បង្ហាញទស្សនៈការពង្រឹងប្រព័ន្ធសុខាភិបាល ។
- ○ បានធ្វើការត្រួតពិនិត្យមើលពីសមាជិកភាពគណៈកម្មាធិការសម្របសម្រួលប្រចាំប្រទេស ចំពោះអ្នកដែលខកខាន មិនបានចូលរួម និង អ្នកជំនួស ។
- ○ បានពិភាក្សាលើ ៖១). ហិរញ្ញប្បទានធនធានមនុស្ស(តាមគំរូ ហិរញ្ញប្បទានថ្មី) ២). ការិយាល័យលេខាធិការដ្ឋានគណៈកម្មាធិការសម្របសម្រួលប្រចាំប្រទេស និង វិបស្សនារបស់គណៈកម្មាធិការសម្របសម្រួល ។

- នៅថ្ងៃទី៩ ខែមករា ឆ្នាំ២០១៥ ឯ.ឧ. ទេសរដ្ឋមន្ត្រី អៀង មូលី បានអញ្ជើញចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការនាយករដ្ឋមន្ត្រី (វិមានសន្តិភាព) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។ កិច្ចប្រជុំបានបង្ហាញពី ១).សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ២).សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា២៧ មាត្រា២៨ មាត្រា៤២ និង មាត្រា៧៤ ស្តីពីច្បាប់អគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា និង ៣). សេចក្តីព្រាងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៥-២០១៨។
- នៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ឯ.ឧ. ទេសរដ្ឋមន្ត្រី អៀង មូលី បានអញ្ជើញជាអធិបតីតំណាងរាជរដ្ឋាភិបាលកម្ពុជា ក្នុងពិធីអបអរសាទរពិធីបុណ្យឯករាជ្យជាតិសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា លើកទី៦៧នៅសណ្ឋាគារ អាំងទែកុងទីណង់តាល់ រាជធានីភ្នំពេញ។ ជាលទ្ធផលនៃកិច្ចប្រជុំរួមមាន ៖
  - ○ ឯ.ឧ. ទេសរដ្ឋមន្ត្រី បានសម្តែងនូវការស្វាគមន៍ និង ថ្លែងអំណរគុណចំពោះអ្នកចូលរួម។
  - ○ ឯកអគ្គរដ្ឋទូតសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ាប្រចាំកម្ពុជាបាន ថ្លែងសុន្ទរកថា រំលឹកពីចំណងការទូតរវាងមីយ៉ាន់ម៉ា និង កម្ពុជា។
  - ○ ឯ.ឧ. ទេសរដ្ឋមន្ត្រី បានសម្តែងនូវការគាំទ្រមីយ៉ាន់ម៉ាឱ្យធ្វើជាម្ចាស់ផ្ទះ រៀបចំកិច្ចប្រជុំកំពូលនៅឆ្នាំ២០១៤។
  - ○ ឯ.ឧ.ទេសរដ្ឋមន្ត្រីបានថ្លែងអបអរសាទរចំពោះរដ្ឋាភិបាល និង ប្រជាជនមីយ៉ាន់ម៉ា ដែលបានរៀបចំកិច្ចប្រជុំកំពូលអាស៊ានលើកទី២៤ និង ២៥ នៅ ណៃពិដោ ប្រកបដោយជោគជ័យ។

## ២.២- លទ្ធផលរបស់អគ្គលេខាធិការដ្ឋាន:

### ២.២.១- លទ្ធផលនៃការរៀបចំសម្របសម្រួលដឹកនាំថ្នាក់ជាតិ

## ២.៣- នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ (PMERD)

នៅក្នុង ខែមករា ឆ្នាំ២០១៥នេះ នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ (PMERD) បាន អនុវត្ត និងសម្រេចការងារ មួយចំនួនដូចខាងក្រោម៖

### ២.៣.១- ការរៀបចំរបាយការណ៍វឌ្ឍនភាពទូលំទូលាយ និង ពហុវិស័យឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍និងជំងឺអេដស៍ប្រចាំត្រីមាសទី៣ ឆ្នាំ២០១៤

នៅក្នុងខែមករាឆ្នាំ២០១៥ នាយកដ្ឋានបានបញ្ចប់របាយការណ៍វឌ្ឍនភាពទូលំទូលលាយ និងពហុវិស័យឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍និងជំងឺអេដស៍ប្រចាំត្រីមាសទី៣ឆ្នាំ២០១៤។នៅក្នុងត្រីមាសនេះ យើងទទួលបានរបាយការណ៍ចំនួន ២៣ (១៤ខេត្ត និង ៩ ក្រសួង) ពីស្ថាប័នរាជរដ្ឋាភិបាល និង ចំនួនមួយពីអង្គការសង្គមស៊ីវិល ។ របាយការណ៍នេះបានបញ្ចប់នៅក្នុងខែមករានេះ ។

### ២.៣.២- ការរៀបចំគម្រោងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតប ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍លើកទី៤ ឆ្នាំ ២០១៦-២០២០ (NSPIV)

នៅក្នុងដំណើរការរៀបចំNSP IV នេះនាយកដ្ឋានមមារញឹកក្នុងការសម្របសម្រួលក្នុងការរៀបចំកិច្ចប្រជុំសិក្ខាសាលាដែលក្នុងនោះរួមមាន៖

- នៅថ្ងៃទី៩ខែមករាឆ្នាំ២០១៥ បានរៀបចំកិច្ចប្រជុំក្រុមការងារស្នូលដែលទាក់ទងនឹងក្រុមការងារបច្ចេកទេស ការបង្ការ ការព្យាបាល ថែទាំ និងគាំទ្រ ព្រមទាំងការកាត់បន្ថយផលប៉ះពាល់នៃមេរោគអេដស៍ / ជំងឺអេដស៍ ដើម្បីរៀបចំធ្វើ SRA ដោយមានអ្នកចូលរួមសរុបមានចំនួន ២០នាក់ នាសាលប្រជុំអ.ជ.ប.ជ.អ ។ សមាសភាពអ្នកចូលរួម ក្នុងនោះមានសមាជិក លេខាធិការដ្ឋានអេដស៍ក្រសួង អង្គការមិនមែនរដ្ឋាភិបាល និងអន្តរជាតិ មួយចំនួន ដែលជាសមាជិក ក្រុមការងារស្នូល ។
- នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០១៥ បានរៀបចំកិច្ចប្រជុំក្រុមការងារស្នូល ដែលទាក់ទងនឹង ក្រុមការងារបច្ចេកទេសការបង្កបរិយាកាសគាំទ្រច្បាប់ និងគោលនយោបាយមគ្គុទេសន៍ភាព និងការសម្របសម្រួលដៃគូពាក់ព័ន្ធ ព្រមទាំង ព័ត៌មានជាយុទ្ធសាស្ត្រ នៃការតាមដាន និងវាយតំលៃ ដើម្បីរៀបចំធ្វើ SRA ដោយមានអ្នកចូលរួមសរុបមានចំនួន១៣នាក់នាសាលប្រជុំអ.ជ.ប.ជ.អ ។ សមាសភាពអ្នកចូលរួមក្នុងនោះមានសមាជិកលេខាធិការដ្ឋានអេដស៍ក្រសួង អង្គការមិនមែនរដ្ឋាភិបាល និងអន្តរជាតិ មួយចំនួនដែលជាសមាជិកក្រុម ការងារស្នូល ។
- នៅថ្ងៃទី១៦ខែមករាឆ្នាំ២០១៥ បានរៀបចំកិច្ចប្រជុំក្រុមការងារជាមួយ ទីប្រឹក្សាបច្ចេកទេស (Consultans) ក្នុងការត្រៀមរៀបចំការសម្របសម្រួល និងរៀបចំដំណើរការសម្រាប់ធ្វើសិក្ខាសាលាថ្នាក់ជាតិ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៥។ ដោយមានអ្នកចូលរួមសរុបមានចំនួន ១២នាក់ នាសាលប្រជុំអ.ជ.ប.ជ.អ ។ សមាសភាពអ្នកចូលរួម ក្នុងនោះមានសមាជិក លេខាធិការដ្ឋានអេដស៍ក្រសួង អង្គការមិនមែនរដ្ឋាភិបាល ជាតិ និង អន្តរជាតិ មួយចំនួន ដែលជាសមាជិក ក្រុមការងារស្នូល ។

- ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៥ បានរៀបចំសិក្ខាសាលា ពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី ការពិនិត្យឡើងវិញលើការអនុវត្តន៍ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ ពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ លើកទី ៣ (២០១១ - ២០១៥) (Validate SRA and Recommendation for NSP IV) ដោយមានអ្នកចូលរួមសរុបមានចំនួន ៨៦ នាក់ នាភោជនីយដ្ឋាន ទន្លេបាសាក់ ២ ។ សមាសភាពអ្នកចូលរួម ក្នុងនោះមានសមាជិក លេខាធិការដ្ឋានអេដស៍ ខេត្ត ក្រុង ទាំង២៦ អង្គការមិនមែនរដ្ឋាភិបាល និងអន្តរជាតិ មួយចំនួន ដែលជាសមាជិក ក្រុមការងារស្នូល ។
- ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥នេះ បានរៀបចំកិច្ចប្រជុំ (Core Group meeting on SRA/NSPIV) ដើម្បីពិនិត្យមើលកម្មវត្ថុរបស់យុទ្ធសាស្ត្រនិមួយៗដោយផ្អែកលើ លទ្ធផលដែលបានមកពីលទ្ធផលនៃសិក្ខាសាលាកាលពីថ្ងៃទី១៩ខែ មករាឆ្នាំ ២០១៥ ។ ដោយមានអ្នកចូលរួមសរុបមានចំនួន ១៩នាក់ នាសាលប្រជុំអ.ជ.ប.ជ.អ។ សមាសភាពអ្នកចូលរួមក្នុងនោះមាន សមាជិកលេខាធិការដ្ឋានអេដស៍ ក្រសួង-មន្ទីរ អង្គការមិនមែនរដ្ឋាភិបាល និងអន្តរជាតិមួយចំនួនដែលជាសមាជិកក្រុមការងារអេដស៍ ។
- ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៥នេះដែរ បានរៀបចំកិច្ចប្រជុំផ្ទៀងផ្ទាត់ លើបច្ចុប្បន្នភាព ស្ថានភាព និងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដើម្បីកំណត់នូវសកម្មភាពសំខាន់ សម្រាប់កំណត់សូចនាករ ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រជាតិលើកទី៤ (NSP IV—Logframe ) ដើម្បីពិនិត្យមើលកម្មវត្ថុរបស់យុទ្ធសាស្ត្រនិមួយៗ ។ កិច្ចប្រជុំបានបែងចែកជាក្រុមពិភាក្សា ទៅលើកម្មវត្ថុរបស់យុទ្ធសាស្ត្រនិមួយ និង បានបង្កើតនូវសកម្មភាពសំខាន់ៗសំរាប់គាំទ្រឲ្យសំរេចបានទៅតាមកម្មវត្ថុទាំងនោះ ។ដោយមានអ្នក ចូលរួមសរុបមានចំនួន ៣៨ នាក់ នាសាលប្រជុំអ.ជ.ប.ជ.អ ។ សមាសភាពអ្នកចូលរួម ក្នុងនោះមានសមាជិកលេខាធិការដ្ឋានអេដស៍ ក្រសួង- មន្ទីរ ខេត្ត ក្រុង ទាំង២៦ អង្គការមិនមែនរដ្ឋាភិបាល និងអន្តរជាតិ មួយចំនួន ដែលជាសមាជិក ក្រុមការងារអេដស៍ ។
- បន្តការពិភាក្សានិងរៀបចំផែនការសកម្មភាពបន្តក្នុងការប្រមូលព័ត៌មានបន្ថែមជាមួយទីប្រឹក្សាបច្ចេកទេស។

### ២.៣.៣-សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតស្តីពីការផ្ទៀងផ្ទាត់ទៅលើសេចក្តីព្រាងឯកសារ យេនឌ័រ និង មេរោគអេដស៍ និង ជំងឺអេដស៍ សម្រាប់ដាក់បញ្ចូលទៅក្នុងផែនការ យុទ្ធសាស្ត្រជាតលើកទី៤ (ឆ្នាំ២០១៦-២០២០)

ក្នុងនាមជាសមាជិកក្រុមការងារបច្ចេកទេស យេនឌ័រនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នាយកដ្ឋានបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ថ្នាក់ជាតិស្តីពីការផ្ទៀងផ្ទាត់ទៅលើសេចក្តីព្រាងឯកសារ យេនឌ័រ និងមេរោគអេដស៍ និងជំងឺអេដស៍លើកទី២សម្រាប់ដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រជាតិលើកទី៤ (ឆ្នាំ២០១៦-២០២០)ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២៧ - ២៨ ខែ មករា ឆ្នាំ២០១៥ នៅសណ្ឋាគារសាន់វេ រាជធានីភ្នំពេញ ដោយបានអញ្ជើញសមាជិក-សមាជិកា មកពីតំណាង ក្រសួង-ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍សរុបទាំងអស់ចំនួន៣០រូប។ កិច្ចប្រជុំនេះគឺពិភាក្សាទៅលើ ការវិភាគ ស្ថានភាព និងការឆ្លើយតបយេនឌ័រ ទៅក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍និងជំងឺអេដស៍និងអនុសាសន៍សម្រាប់បញ្ជ្រាប និងបញ្ចូលយេនឌ័រ ទៅក្នុងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយលេកទី ៤ ។ កិច្ចពិភាក្សារយៈពេលពីរថ្ងៃនេះ

ទទួលបាននូវធាតុចូលបន្ថែមសម្រាប់ជាអនុសាសន៍ បញ្ចូលទៅក្នុង NSP IV ។ ហើយឯកសារទាំងស្រុងនឹងបញ្ចប់នៅក្នុងខែមករានេះ ។

### ២.៣.៤- ការផ្គត់ផ្គង់ជំនាញ IT និង ការរៀបចំគេហទំព័រអាជ្ញាធរជាតិប្រយុទ្ធនឹង ជំងឺអេដស៍

(មិនទាន់មានរបាយការណ៍)

### ២.៣.៥-ការរៀបចំរបាយការណ៍វឌ្ឍនភាពប្រយុទ្ធនឹងជំងឺអេដស៍នៅប្រទេសកម្ពុជា (GARPR) សម្រាប់ផ្ញើជូនអង្គការសហប្រជាជាតិ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានតួនាទីដឹកនាំ និងសម្របសម្រួលការរៀបចំរបាយការណ៍សកលនៃការឆ្លើយតបទៅនឹងមេរោគអេដស៍និងជំងឺអេដស៍នូវរៀងរាល់ឆ្នាំ។នៅក្នុងខែមករានេះនាយកដ្ឋានបានចាប់ផ្ដើមសកម្មភាព ក្នុងនោះការរៀបចំ (GARPR) មានដូចជា៖

- នាយកដ្ឋានបានទទួលE-mail ក្នុងការរៀបចំ GARPR ២០១៥ ដែលត្រូវបញ្ជូនរបាយការណ៍ នៅថ្ងៃទី៣១ ខែ មិនា ឆ្នាំ២០១៥ ។
- បានរៀបចំលិខិតទៅ PR-NCHADS ទាក់ទងនឹងការជ្រើសរើស ជំនួយការបច្ចេកទេស (TA) សម្រាប់រៀបចំរបាយការណ៍នេះ ។
- រៀបចំផែនការលម្អិត សម្រាប់ការងារនេះ ។

### ២.៣.៦- គម្រោងមូលនិធិសាកលជំហានទី២ ( Single Stream Fund )

នៅក្នុងខែមករានេះ សម្រេចបាននូវលទ្ធផលមួយចំនួនដូចខាងក្រោម៖

- បានធ្វើរបាយការណ៍ វឌ្ឍនភាពសំរាប់ការអនុវត្តសកម្មភាពរបស់គំរោងមូលនិធិសកល PUDR ៨ និង បញ្ជូនទៅ PR-NCHADS និងរង់ចាំ ការចូលរួមប្រជុំ ប្រចាំត្រីមាសជាមួយ PR-NCHADS។
- បានរៀបចំធ្វើតម្រូវការថវិកាលំអិតសម្រាប់ សកម្មភាពដែលត្រូវបានយកមកពី (carry Foreward) ឆ្នាំ ២០១៤ មកប្រើក្នុងឆ្នាំ២០១៥ ដល់ខែ មិថុនា ទាំងអស់ មាន១១ កូដ គឺសម្រាប់ ធ្វើផែនការយុទ្ធសាស្ត្រជាតិលើកទី៤ ធ្វើ GARPR និង សំភារៈការិយាល័យ ។ បន្ទាប់ពីបានការឯកភាព ពីថ្នាក់ដឹកនាំ ឯកសារនេះបានបញ្ជូនទៅ ខាង PR- NCHADS រួចរាល់។
- បានចូលរួមកិច្ចប្រជុំ គណៈកម្មការគ្រប់គ្រងការអនុវត្តន៍ ថវិកាគំរោង ។ អង្គប្រជុំបានពិនិត្យលើកិច្ចការមួយចំនួនដែលចាំបាច់ត្រូវធ្វើ មានដូចជា ការសុំកាត់បន្ថយថវិកា មូលនិធិសកល ក្នុងរង្វង់ដែលកំណត់មូលនិធិសកល ដាក់បញ្ចូលថវិកាសំរាប់ TA IT ទៅក្នុងការដកថវិកាសំរាប់ អ្នកបើកបរទាំង ៤ និង ទុក TA finance ២នាក់ សំរាប់រយៈពេលគ្រប់៦ខែ ។

### ២.៣.៧- ការរៀបចំរបាយការណ៍ និងកំណត់ហេតុនៃកិច្ចប្រជុំជាទៀងទាត់

នាយកដ្ឋានបានធ្វើការសម្របសម្រួល និងរៀបចំចងក្រងរបាយការណ៍សម្រាប់ផ្ដល់ជាព័ត៌មានដល់ថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍មួយចំនួនស្ដីពី៖

- របាយការណ៍កិច្ចប្រជុំប្រចាំសប្តាហ៍ របស់នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ ចំនួន០២ ដង។
- របាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ របស់អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ចំនួន ០៣ដង ។
- របាយការណ៍ប្រចាំខែមករា ឆ្នាំ២០១៥ របស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

## ២.៤-ចន្លោះភាព និងសមិទ្ធផលដែលសម្រេចបានដោយនាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន

នៅក្នុងខែមករា ឆ្នាំ២០១៥នេះ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន បានអនុវត្ត និងសម្រេចនូវលទ្ធផល មួយចំនួនដូចខាងក្រោម៖

- បានចូលរួមប្រជុំបច្ចេកទេសចំនួនបួនលើកនៅ អ.ជ.ប.ជ.អ
- ចូលរួមប្រជុំជាមួយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្តព្រៃវែង
- បានចុះវិភាគស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍ នៅខេត្តព្រៃវែង ដើម្បីធ្វើពង្រាងគំរោងផែនការយុទ្ធសាស្ត្រជាតិលើកទី៤
- បានចូលរួមប្រជុំក្រុមស្នូល និងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការធ្វើពង្រាងគំរោងផែនការយុទ្ធសាស្ត្រជាតិលើកទី៤
- បានធ្វើគំរោងផែនការសកម្មភាពប្រចាំឆ្នាំ២០១៥ របស់នាយកដ្ឋាន

## ២.៥-ចន្លោះភាព និងសមិទ្ធផលដែលសម្រេចបានដោយនាយកដ្ឋាន បង្ការ ថែទាំ និង គាំទ្រ

នៅក្នុងខែ មករា ឆ្នាំ២០១៥នេះ នាយកដ្ឋានបង្ការ ថែទាំ និងគាំទ្រ បានអនុវត្ត និងសម្រេចនូវលទ្ធផល មួយចំនួនដូចខាងក្រោម៖

- បានរៀបចំគម្រោងផែនការសកម្មភាពរបស់នាយកដ្ឋានសម្រាប់ឆ្នាំ ២០១៥។
- ជួយដល់ក្រសួងសង្គមកិច្ចក្នុងការរៀបចំកម្មវិធីសម្រាប់ចុះអប់រំដល់កុមារដែលងាយរងគ្រោះដោយសារ មេរោគអេដស៍ និងជំងឺអេដស៍នៅខេត្តកណ្តាល។
- ចូលរួមសម្របសម្រួលក្នុងសិក្ខាសាលាស្តីពីការធ្វើបច្ចុប្បន្នភាពស្ថានភាព និងការឆ្លើយតបនិងមេរោគអេដស៍ និងជំងឺអេដស៍ សម្រាប់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រជាតិលើកទី៤ (២០១៦- ២០២០) នៅថ្ងៃទី ១៩ មករា ឆ្នាំ ២០១៥ នៅភោជនីយដ្ឋានទន្លេបាសាក់ ២។
- ចុះពិនិត្យស្ថានភាពមេរោគអេដស៍/ជំងឺអេដស៍ ដើម្បីដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រជាតិលើកទី៤ នៅ ខេត្តព្រៃវែង ពីថ្ងៃទី ៤-៦ មករា ឆ្នាំ២០១៥។
- ចូលរួមប្រជុំក្រុមបច្ចេកទេសថ្នាក់ជាតិដើម្បីលើកផែនការយុទ្ធសាស្ត្រជាតិលើកទី៤ (២០១៦ - ២០២០)។

## ២.៦- ចង្រ្កានភាព និង សមិទ្ធផលដែលសម្រេចបាន ដោយនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ

នៅក្នុងខែ មករា ឆ្នាំ២០១៥នេះ នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ បានអនុវត្ត និង សម្រេចនូវលទ្ធផលមួយចំនួនដូចខាងក្រោម៖

### ២.៦.១- ការិយាល័យរដ្ឋបាល និងរបៀប

ក្នុងខែមករា ឆ្នាំ២០១៣ នេះការិយាល័យរដ្ឋបាល-របៀបបានអនុវត្តការងារដូចខាងក្រោម៖

- ប្រមូលឯកសារឆ្នាំ ២០១៤ រក្សាទុក និងបង្កើត File ថ្មី សម្រាប់ឆ្នាំ ២០១៥
- រៀបចំឯកសារស្នើសុំបុគ្គលិកជាប់កិច្ចសន្យា និងអណ្តែត ទៅក្រសួងសុខាភិបាលសម្រាប់ឆ្នាំ ២០១៥
- បានទទួលលិខិតចូលចំនួន ២៥
- បានបញ្ជូនលិខិតចេញ ១៨
- បានរៀបចំលិខិតបេសកកម្មជូនថ្នាក់ដឹកនាំ មន្ត្រី ចំណាយថវិកាជាតិចំនួន ១៨
- បានរៀបចំលិខិតអញ្ជើញប្រជុំថ្នាក់ដឹកនាំ និង បច្ចេកទេស ១១
- បានរៀបចំបន្ទប់ប្រជុំចំនួន ៥ ដង

### ២.៦.២- ការិយាល័យបុគ្គលិក និងបៀវត្សពលកម្ម

ក្នុងខែមករា ឆ្នាំ២០១៣នេះ ការិយាល័យបុគ្គលិក និងបៀវត្សពលកម្ម បានអនុវត្តការងារដូចខាងក្រោម៖

- បានទទួលលិខិតចូលចំនួន ៤៥
- បានបញ្ជូនលិខិតចេញ ៣០
- បានរៀបចំទំរង់បែបបទស្នើសុំបម្រើការងារជាបុគ្គលិកជាប់កិច្ចសន្យាសម្រាប់ឆ្នាំ ២០១៥
- បានរៀបចំលិខិតបេសកកម្មជូនថ្នាក់ដឹកនាំ មន្ត្រី ចំណាយថវិកាជាតិចំនួន ៦
- បានរៀបចំលិខិតអញ្ជើញសំរាប់កិច្ចប្រជុំថ្នាក់ដឹកនាំ ប្រជុំបច្ចេកទេស និងប្រជុំរួម
- បានរៀបចំលិខិតឧទ្ទេសនាមចូលរួមទទួល និងជូនដំណើរគណៈប្រតិភូជាន់ខ្ពស់របស់សាធារណៈរដ្ឋសង្គមនិយមវៀតណាម

### ២.៦.៣- ការិយាល័យផ្គត់ផ្គង់ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

ក្នុងខែមករា ឆ្នាំ២០១៥ នេះ ការិយាល័យផ្គត់ផ្គង់និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ មិនទាន់មានរបាយការណ៍ក្នុងការអនុវត្តការងារនៅឡើយទេ។

### ២.៦.៤- ការិយាល័យថវិកា និងហិរញ្ញវត្ថុ

ក្នុងខែមករា ឆ្នាំ២០១៥នេះ ការិយាល័យថវិកា និងហិរញ្ញវត្ថុបានអនុវត្តការងារដូចខាងក្រោម៖

**ក-ថវិកាជាតិ**

- បានរៀបចំរបាយការណ៍ចំណូល ចំណាយថវិកាជាតិ និងជំនួយ ឆ្នាំ២០១៤
- បានកែតម្រូវផែនការថវិកាឆ្នាំ២០១៥ តម្រូវទៅតាមផែនការថវិកាដែលបានអនុម័តដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល
- បានរៀបចំជុំរដ្ឋទេយ្យដើម្បីស្នើសុំការអនុម័តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានរៀបចំបែងចែកសម្ភារៈប្រចាំត្រីមាសជូនថ្នាក់ដឹកនាំ និងគ្រប់នាយកដ្ឋាន

**ខ-ថវិកាជំនួយ**

- បានធ្វើការកែតម្រូវផែនការថវិកាតាមការស្នើសុំរបស់របស់ ឯ.ឧ.ទា ផលា
- បានចូលរួមកិច្ចប្រជុំជាមួយ PR- NCHADS ស្ដីអំពីទំរង់របាយការណ៍ថ្មីសម្រាប់ PUDR
- បានរៀបចំឯកសារនិងចុះកិច្ចសន្យាសម្រាប់ទីប្រឹក្សាបច្ចេកទេសបានផែនការថវិកាសម្រាប់ប្រាក់បៀវត្សបុគ្គលិក
- បានរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ខែ១២ ឆ្នាំ២០១៤
- បានរៀបចំការវាយតំលៃនិងចុះកិច្ចសន្យាជាថ្មីសម្រាប់ជំនួយការបច្ចេកទេស
- បានចូលរួមកិច្ចប្រជុំជាមួយPR-NCHADS ស្ដីអំពីការកាត់បន្ថយថវិកាគំរោងមូលនិធិសាកល
- បានរៀបចំរបាយការណ៍ចំណាយប្រចាំថ្ងៃ របាយការណ៍ទូទៅ របាយការណ៍គណនេយ្យ ជាទៀងទាត់ដាក់ជូនថ្នាក់ដឹកនាំ។

### ២.៦.៥- ការិយាល័យគណនេយ្យ

ក្នុងខែមករា ឆ្នាំ ២០១៥ នេះ ការិយាល័យគណនេយ្យបានអនុវត្តការងារដូចខាងក្រោម ៖

**ក-ថវិកាជាតិ:**

- បានរៀបចំទូទាត់ការចំណាយរៀបចំទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍តាមបណ្ដារាជធានី ខេត្ត បញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានរៀបចំទូទាត់គ្រង់បេសសកម្មក្នុងប្រទេសបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានរៀបចំទូទាត់ចំណាយការប្រើប្រាស់ទឹក ភ្លើង ទូរស័ព្ទ សំរាម បង់ពន្ធលើមធ្យោបាយដឹកជញ្ជូន
- បានរៀបចំឯកសារទូទាត់ចំណាយកិច្ចប្រជុំ CEDAW ចំនួន១លើក
- បានរៀបចំទូទាត់ចំណាយកិច្ចប្រជុំតាមបណ្ដាខេត្ត និងស្រុក
- បានរៀបចំឯកសារទូទាត់ចំណាយកិច្ចប្រជុំ GDJ ចំនួន១លើក
- បានរៀបចំបិទបញ្ជីចំណូលចំណាយថវិកាជាតិសម្រាប់ឆ្នាំ ២០១៤
- បានចូលរួមកិច្ចប្រជុំរួមប្រចាំខែ ធ្នូ របស់អគ្គលេខាធិការដ្ឋានអ.ជ.ប.ជ.អ
- បានរៀបចំរបាយការណ៍ស្ដីពីការបញ្ចូលបញ្ចេញសម្ភារៈផ្សព្វផ្សាយអំពីជំងឺអេដស៍ សម្ភារៈការិយាល័យ គ្រឿងសង្ហារឹម សម្ភារៈសំអាត និងអនាម័យ និងសម្ភារៈបរិក្ខារបច្ចេកទេស ប្រចាំខែធ្នូ

**ខ-ផ្នែករដ្ឋបាល:**

- បានទំនាក់ទំនងទៅ PR ទាក់ទងនឹង contract សំរាប់ទីប្រឹក្សាអន្តរជាតិសំរាប់ការងារ NSPIV
- រៀបចំធ្វើបច្ចុប្បន្នភាពការងារគណនេយ្យប្រចាំថ្ងៃ
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ
- បានរៀបចំឯកសារចំណាយលើប្រេងសាំង អ៊ីនធឺណែត និង សំភារៈការិយាល័យ
- រៀបចំផែនការថវិកាក្នុងគំរោងមូលនិធិសាកលជុំទី២ដែលត្រូវកាត់កង។

# ៣-ផែនការសកម្មភាព និង ទិសដៅសម្រាប់ ខែ កុម្ភៈ ឆ្នាំ២០១៥

## ៣-១- នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និង ស្រាវជ្រាវ

- បន្តការរៀបចំបញ្ចប់ SRA និង រៀបចំNSP IV៖
    - សម្របសម្រួលជាមួយ ទីប្រឹក្សា ក្នុងការរៀបចំផែនការលំអិតបន្ត
    - ចុះជួបជាមួយ ក្រុមគោលដៅគន្លឹះ តាមក្រសួង
    - រៀបចំសិក្ខាសាលាតាមក្រុមការងារបច្ចេកទេសដើម្បីបន្តការរៀបចំ Logframe
    - បញ្ចប់ SRA និងដាក់ជូន ថ្នាក់ដឹកនាំ ពិនិត្យ
- ការរៀបចំរបាយការណ៍ GARPR
    - បន្តការងារជ្រើសរើសTA
    - រៀបចំលិខិតទៅក្រសួងពាក់ព័ន្ធ
    - រៀបចំទម្រង់ប្រមូលទិនន្ន័យ
    - ចុះប្រមូលទិនន្ន័យ
    - រៀបចំសិក្ខាសាលាថ្នាក់ជាតិ
- របាយការណ៍វឌ្ឍនភាព
    - បន្តរៀបចំរបាយការណ៍ត្រីមាសទីបួន
    - របាយការណ៍មូលនិធិសកល
    - របាយការណ៍ ការងារ យេនឌ័រ
- និងចូលរួមសកម្មភាពផ្សេងៗ ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

## ៣-២- នាយកដ្ឋាន បង្ការ ថែទាំ និងគាំទ្រ

- ពិនិត្យលើការរៀបចំគម្រោងផែនការសកម្មភាពសម្រាប់ឆ្នាំ ២០១៥ ។
- ចុះអភិបាលកិច្ច លើការអនុវត្តន៍ការងារឆ្លើយតបទៅនិងការកាត់បន្ថយការរាលដាលនៃមេរោគអេដស៍ និង ជំងឺអេដស៍នៅតាមបណ្តាខេត្ត ។
- ចូលរួមកិច្ចប្រជុំនានាដើម្បីពង្រឹងកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធក្នុងការឆ្លើយតបទៅនិងការកាត់បន្ថយការរាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍។

- តាមដាន និងពិនិត្យរាល់ការអនុវត្តន៍ការងារឆ្លើយតបទៅនិងការកាត់បន្ថយការរាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍របស់ស្ថាប័នពាក់ព័ន្ធ ។

### ៣-៣- នាយកដ្ឋាន ទាក់ទង និង ចលនាប្រភពធនធាន

- បន្តចូលរួមប្រជុំជាមួយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត
- បន្តការចូលរួមការធ្វើពង្រាងគំរោងផែនការយុទ្ធសាស្ត្រជាតិលើកទី៤

### ៣-៤- នាយកដ្ឋាន រដ្ឋបាល និង ហិរញ្ញវត្ថុ

- រៀបចំគោលការណ៍ស្នើសុំចំណាយទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវៈ គ្រឿងសង្ហារឹម សម្ភារៈបរិក្ខារបច្ចេកទេស សម្ភារៈការិយាល័យ សម្ភារៈផ្សព្វផ្សាយសម្រាប់ឆ្នាំ ២០១៥
- រៀបចំឯកសារស្នើសុំ និងទូទាត់ការចំណាយថវិកាជាតិសម្រាប់រដ្ឋបាលផ្ទៃក្នុងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- រៀបចំបេសកកម្មជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការចុះបំពេញការងារតាមបណ្តាខេត្ត
- រៀបចំឯកសារស្នើសុំប្រាក់បៀវត្សបុគ្គលិកជាប់កិច្ចសន្យា និងអណ្តែត ទៅក្រសួងសុខាភិបាលសម្រាប់ខែកុម្ភៈ ២០១៥
- រៀបចំឯកសារចំណាយរួច ដើម្បីទូទាត់ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានរតនាគារជាតិដើម្បីស្នើសុំដកសាច់ប្រាក់បន្ត
- រៀបចំទូទាត់ប្រាក់បេសកកម្មជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការដែលបានចុះបំពេញការងារតាមបណ្តាខេត្ត
- រៀបចំរបាយការណ៍ PUDR
- រៀបចំរបាយការណ៍ EFR
- រៀបចំបន្តការចុះកិច្ចសន្យាសម្រាប់ជំនួយការបច្ចេកទេស
- សម្របសម្រួលការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់រៀបចំ SRA និង NSPIV
- រៀបចំចុះកិច្ចសន្យាការងារជាមួយកញ្ញា គឹម ស្រេង
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ
- បិទបញ្ជីរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០១៤
- រៀបចំការចំណាយប្រាក់លើកទឹកចិត្តបុគ្គលិកសម្រាប់ឆ្នាំ២០១៤ ( incentive payment )
- រៀបចំឯកសារ សម្រាប់សាវនកម្ម ឆ្នាំ២០១៤
- បន្តកិច្ចសហការ និងសម្របសម្រួលជាមួយបណ្តានាយកដ្ឋានជំនាញទាំងបីដើម្បីជំរុញនិងពង្រឹងការងាររបស់អាជ្ញាធរជាត្រិយុទ្ធនឹងជំងឺអេដស៍ឱ្យកាន់តែប្រសើរ។

-------------------------------